# សហព័ន្ធខ្មែរកម្ពុជាក្រោម

KHMERS KAMPUCHEA-KROM FEDERATION

ASIA – AUSTRALIA – EUROPE – NORTH AMERICA - A MEMBER OF UNPO - IDB

KKF- P.O. Box 0193 • Pennsauken • NJ 08110 • Tel: (856) 655-3838 • Fax: (856) 583-1503

http://www.khmerkrom.org E-mail: thach.thach@khmerkrom.org


---

## ទិវាកម្ពុជាក្រោម

## ខួបរំលឹកនៃការបាត់បង់ទឹកដីកម្ពុជាក្រោមថ្ងៃទី៤ខែឧសភាឆ្នាំ១៩៤៩

ទីក្រុងប៉ារិស ប្រទេសបារាំង

ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៩

រាងរាល់ឆ្នាំ ជនរួមឈាមខ្មែរក្រោមបានធ្វើពិធីខួបរំលឹកថ្ងៃបាត់បងទឹកដីកម្ពុជាក្រោម គឺថ្ងៃទី៤ខែឧសភា ឆ្នាំ១៩៤៩ ជាថ្ងៃដែលរដ្ឋាភិបាលបារាំងបានប្រគល់អោយរដ្ឋាភិបាលយួនបាវដាយបន្តធ្វើអាណានិគមមកលើទឹកដីកម្ពុជាក្រោម។

ឆ្នាំនេះជាខួបគម្រប់ទី៦០នៃការបាត់បង់ទឹកដីកម្ពុជាក្រោម។ សហព័ន្ធខ្មែរកម្ពុជាក្រោមនឹងរៀបចំទីវាកម្ពុជាក្រោមនៅប្រទេសបារាំងដែលជាកន្លែងប្រព្រឹត្តនូវព្រឹត្តិការណ៍ប្រវត្តិសាស្រ្តដ៏អយុត្តិធម៌មកលើជាតិខ្មែរ។

ទិវាកម្ពុជាក្រោម និងរំលឹកឡើងនូវប្រវត្តិសាស្រ្ត ការតស៊ូដ៏អងអាចក្លាហានរបស់វិរសមណៈនិងវិរបុរសជាតិដែលបានបូជាជីវិតរបស់ខ្លួនដើម្បីរក្សានូវវប្បធម៌ អក្សរសាស្រ្ត។ល។ ឲ្យបានគង់រហូតមកដល់បច្ចុប្បន្នកាលនេះ។ ទិវាកម្ពុជាក្រោម ជាទិវាបង្ករលកណ្ឌៈសាមគ្គីជាតិ សេចក្តីក្លាហាន ពង្រឹងស្មារតីស្នេហាជាតិ សេចក្តីស្មោះត្រង់ចំពោះជាតិនិងជនរួមឈាមខ្មែរក្រោមដែលកំពុងរងគ្រោះដោយនឹមអាណានិគមយួនហាណូយ។

គោលបំណងទិវាកម្ពុជាក្រោមមាន៣ចំណុចៈ

- ចងចាំនូវប្រវត្តិសាស្រ្តដ៏អាស្រូវ ដើម្បីរកមធ្យោបាយបញ្ឈប់រាល់អំពើអាណានិគមនិយមមកលើខ្មែរក្រោម
- ដំឡើងសាមគ្គីជាតិដើម្បីបង្រ្កាបរាល់មហិច្ឆិតាលេបទឹកដីខ្មែរនាបច្ចុបន្ននឹងក្នុងអនាគតដោយបរទេស
- ប្តេជ្ញាតស៊ូដើម្បីការពារព្រលឹងជាតិ ការពារវប្បធម៌ អារ្យធម៌ អក្សរសាស្រ្តខ្មែរ និងធ្វើឲ្យខ្មែរក្រោមមានសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯង

ទិវាកម្ពុជាក្រោម ដែលនិងប្រារព្ធឡើងនៅ ថ្ងៃទី១៣ខែឧសភាឆ្នាំ២០០៩ នាទីក្រុងប៉ារិស ប្រទេសបារាំង និងមានការចូលរួមពីភ្ញៀវបរទេសនឹងជនរួបជាតិមកពីនានាប្រទេសទូទាំង៤ទ្វីប។

ចំពោះព្រះថេរានុថេរៈ ជនរួមឈាមដែលមានបំណងទៅចូលរួមនៅប្រទេសបារាំង សូមមេត្តាទាក់ទងតាមសាខាឬ ការិយាល័យសហព័ន្ធតាមអស័យដ្ឋាននិងទូរស័ព្ទខាងក្រោម។

E-mail: giap.tran@khmerkrom.org or europe.fkk@gmail.com

Telephone: 856-655-3838

សូមមេត្តាទទួលនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំព្រះករុណាខ្ញុំបាទ។

ធ្វើនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩

ថាច់ ង៉ុក ថាច់

ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម

សេចក្តីបន្ថែម

ចំពោះសាខាសហព័ន្ធ សមាគម វត្តនិងជនរួមឈាមខ្មែរដែលបានរៀបចំធ្វើពិធីរំលឹកឃួបបាត់បង់ទឹកដីដូចសព្វឆ្នាំ នោះសូមមេត្តារៀបចំឲ្យបានអឹកកធឹកនិងឲ្យមានលក្ខណៈពិសេសនាទិវាកម្ពុជាក្រោមយើងនេះ។